ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៤២ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានសម្រាប់ឆ្នាំ២០១៥ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីកាអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", នៅក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ ២** : ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤** : នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ត្រាំ អ៊ីវតឹក

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការនិងដឹកជញ្ជូន

## តារាងឧបសម្ព័ន្ធវិនិយោគមូលធនប្រចាំឆ្នាំ ២០១៥ (ធនធានថវិកាជាតិ)

## របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យ បុរេប្រទាន | ឥណទាន ទូទាត់ ធម្មតា | ឥណទាន០១ ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | **សរុបរួម (I+II)** | **10,951,400,000** | **10,951,400,000** | **1,859,945,000** | **9,091,455,000** | **464,986,250** | **16.98%** |
| | | I | ឥណទានតាមជំពូកមិនគិតបញ្ចូលបេសកកម្មក្នុងប្រទេស | **9,838,400,000** | **9,838,400,000** | **1,042,000,000** | **8,796,400,000** | **260,500,000** | **10.59%** |
| 60 | | | ការទិញ | **5,118,400,000** | **5,118,400,000** | **171,000,000** | **4,947,400,000** | **42,750,000** | **3.34%** |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ | **64,000,000** | **64,000,000** | **29,000,000** | **35,000,000** | **7,250,000** | **45.31%** |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតអនាម័យ | 4,000,000 | 4,000,000 | 4,000,000 | | 1,000,000 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទនិងសំណង់ផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 50,000,000 | 50,000,000 | 15,000,000 | 35,000,000 | 3,750,000 | 30.00% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | **3,392,000,000** | **3,392,000,000** | **82,000,000** | **3,310,000,000** | **20,500,000** | **2.42%** |
| | | 60021 | សម្ភារៈការិយាល័យនិងបោះពុម្ព | 3,380,000,000 | 3,380,000,000 | 70,000,000 | 3,310,000,000 | 17,500,000 | 2.07% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 12,000,000 | 12,000,000 | 12,000,000 | | 3,000,000 | 100% |
| | 6005 | | សម្ភារៈតូចតាច សម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ | **1,662,400,000** | **1,662,400,000** | **60,000,000** | **1,602,400,000** | **15,000,000** | **3.61%** |
| | | 60051 | សម្ភារៈនិងបរិក្ខាបច្ចេកទេស | 1,544,400,000 | 1,544,400,000 | 36,000,000 | 1,508,400,000 | 9,000,000 | 2.33% |
| | | 60052 | សម្លៀកបំពាក់ | 100,000,000 | 100,000,000 | 6,000,000 | 94,000,000 | 1,500,000 | 6.00% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 18,000,000 | 18,000,000 | 18,000,000 | | 4,500,000 | 100% |
| 61 | | | សេវាកម្ម | **4,720,000,000** | **4,720,000,000** | **871,000,000** | **3,849,000,000** | **217,750,000** | **18.45%** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6101 | | កិច្ចសន្យានៃការផ្គត់ផ្គង់សេវាជាមួយសហគ្រាស | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | 6105 | | ការថែទាំ និង ជួសជុល | 1,207,000,000 | 1,207,000,000 | 259,000,000 | 948,000,000 | 64,750,000 | 21.46% |
| | | 61052 | ការថែទាំ និង ជួសជុលអគារផ្សេងៗ និង ប្រាសាទ | 730,000,000 | 730,000,000 | 32,000,000 | 698,000,000 | 8,000,000 | 4.38% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 50,000,000 | 50,000,000 | 50,000,000 | | 12,500,000 | 100% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 300,000,000 | 300,000,000 | 50,000,000 | 250,000,000 | 12,500,000 | 16.67% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារ: និង ឧបករណ៍បច្ចេកទេស | 117,000,000 | 117,000,000 | 117,000,000 | - | 29,250,000 | 100% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | 6110 | | ទំនាក់ទំនងសាធារណ: និងផ្សព្វផ្សាយ | 1,865,000,000 | 1,865,000,000 | 287,000,000 | 1,578,000,000 | 71,750,000 | 15.39% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 60,000,000 | 60,000,000 | 18,000,000 | 42,000,000 | 4,500,000 | 30.00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 80,000,000 | 80,000,000 | 24,000,000 | 56,000,000 | 6,000,000 | 30.00% |
| | | 61103 | ប្រជុំ សិក្ខាសាលានិង សន្និសិទ | 1,600,000,000 | 1,600,000,000 | 120,000,000 | 1,480,000,000 | 30,000,000 | 7.50% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 45,000,000 | 45,000,000 | 45,000,000 | - | 11,250,000 | 100% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុងនិងក្រៅប្រទេស | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100% |
| | | 61106 | ចំណាយសម្រាប់តាំងពិព័ណ៌ក្នុងនិងក្រៅប្រទេស | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័តមានសាធារណ: | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100% |
| | 6111 | | ចំណាយលើការជាវសាព័ត៌មាននិងឯកសារ | 5,000,000 | 5,000,000 | 5,000,000 | - | 1,250,000 | 100% |
| | | 61111 | ចំណាយលើការជាវសាព័ត៌មាន | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 1,435,000,000 | 1,435,000,000 | 280,000,000 | 1,155,000,000 | 70,000,000 | 19.51% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 450,000,000 | 450,000,000 | 120,000,000 | 330,000,000 | 30,000,000 | 26.67% |
| | | 61132 | សោហ៊ុយបេសកកម្ម | 230,000,000 | 230,000,000 | 50,000,000 | 180,000,000 | 12,500,000 | 21.74% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 755.000,000 | 755,000,000 | 110,000,000 | 645,000,000 | 27,500,000 | 14.57% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 203,000,000 | 203,000,000 | 35,000,000 | 168,000,000 | 8,750,000 | 17.24% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 5.000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 198,000,000 | 198,000,000 | 30,000,000 | 168,000,000 | 7,500,000 | 15.15% |
| | | 11 | ឥណទានសំរាប់ចំណាយបេសកកម្មក្នុងប្រទេស | 1,113,000,000 | 1,113,000,000 | 817,945,000 | 295,055,000 | 204,486,250 | 73.49% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 1,113,000,000 | 1,113,000,000 | 817,945,000 | 295,055,000 | 204,486,250 | 73.49% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 5,000,000 | 5,000,000 | 5,000,000 | - | 1,250,000 | 100% |
| | | 61122 | សោហ៊ុយបេសកកម្ម | 174,000,000 | 174,000,000 | 130,679,000 | 43,321,000 | 32,669,750 | 75.10% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 934,000,000 | 934,000,000 | 682,266,000 | 251,734,000 | 170,566,500 | 73.05% |

បានឃើញ និង ពិនិត្យត្រឹមត្រូវ

ភ្នំពេញថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥

ៗ. អគ្គនាយក

អគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយករង

មុិញ ប៊ុនសុវណ្ណអាទិច្ចាសីលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ

ភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

ជ. អគ្គនាយក

អគ្គនាយកដ្ឋានថវិកា

ប្រធាននាយកដ្ឋានស្រាវជ្រាវ និងវិភាគគោលនយោបាយ

ឈុយ_សុតតិរក្ស

រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

បានឃើញ និង ពិនិត្យត្រឹមត្រូវ រដ្ឋលេខាធិការប្រចាំការ

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

អ៊ុក_ច័ន្ទតារា

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ម៉ាំ ប៊ុនហេង